clearcambodia
A BETTER LIFE

# សេចក្តីប្រកាសដេញថ្លៃការសាងសង់ផ្លូវ និងទ្វារទឹក

**អង្គការស្អាតកម្ពុជា** គឺជាអង្គការក្នុងស្រុកមួយដែលធ្វើការលើវិស័យអភិវឌ្ឍនៅក្នុងសហគមន៍ដោយលើកកម្ពស់គុណភាពទឹក អនាម័យ សុខភាព និងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋដោយប្រើបច្ចេកវិទ្យា និងការអប់រំសមស្រប។ អង្គការស្អាតកម្ពុជាត្រូវការស្វែងរកជាងដើម្បីចូលរួមដេញថ្លៃសាងសង់ផ្លូវនិងទ្វារទឹកដែលមានទីតាំងនៅ ទំនប់សំរោង ស្ថិតនៅភូមិសំរោង ឃុំស្វាយចេក ស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ។

**១. ភូមិសំរោង ឃុំស្វាយចេក ស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ**

- **ផ្លូវ**ខ្នងទំនប់ ប្រវែង១០០០ ម៉ែត្រ ទទឹងខ្នងលើ៥ ម៉ែត្រ បាតក្រោម៨ ម៉ែត្រ កម្ពស់២.៥ម៉ែត្រ និងចាក់គ្រួសក្រហមពីលើ កិនបង្ហាប់កម្រាស់មួយតឹកកន្លះ (១៥០មម) ទទឹង៤ម៉ែត្រ ប្រវែង១០០០ម៉ែត្រ។
- **ទ្វារទឹក** ទទឹង៤ម៉ែត្រ បណ្តោយ៥ម៉ែត្រ កម្ពស់៣ម៉ែត្រ ប្រវែងស្លាបក្នុង២ម៉ែត្រ ប្រវែងស្លាបក្រៅ៣ម៉ែត្រ ។ល។និង។ល។ សូមមើលឯកសារ ប្លង់លំអិតដែលបានភ្ជាប់មកជាមួយ។

**លក្ខខណ្ឌក្នុងការជ្រើសរើស៖**

- ជាជាងសាងសង់ផ្ទាល់ និងជាជាងដែលមានបទពិសោធន៍ក្នុងការសាងសង់ផ្លូវខ្នងទំនប់ និងទ្វារទឹក។
- តម្លៃដែលដាក់ក្នុងការដេញថ្លៃ ត្រូវបូករួមទាំងសម្ភារ និងឈ្នួលជាងឲ្យរួចជាស្រេច នឹងអាចប្រើប្រាស់បាននៅតាមទីតាំងគោលដៅដូចបានជម្រាបជូនខាងលើ។
- អ្នកដាក់ដេញថ្លៃមិនមែនជាសាច់ញាតិនឹងគ្នា ឬនៅក្នុងក្រុមតែមួយ។ **ឧទាហរណ៍៖** ឪពុកនិងកូនជាជាងក្នុងក្រុមតែមួយ មេជាងកូនជាងនៅក្នុងក្រុមតែមួយ។
- អ្នកដាក់ដេញថ្លៃមិនអាចជាបុគ្គលិក ឬជាបុគ្គលិកស្ម័គ្រចិត្តរបស់អង្គការស្អាតកម្ពុជាឡើយ។

អាស្រ័យដូចបានជំរាបជូនខាងលើសូមលោក លោកស្រីដែលមានចំណាប់អារម្មណ៍លើការដេញថ្លៃការសាងសង់ខាងលើនេះសូបទំនាក់ទំនងទៅកាន់ទូរស័ព្ទលេខ៖

១). លោក យុន យុទ្ធា ០៦៨ ៩៧៤ ០៦៤/០១០ ៩៥៦ ៩៧០ ២). លោក ចាន់ មន្នី ០១២ ៩៩០ ៣៣៦ ឬអាចទាញយកឯកសារដែលពាក់ព័ន្ធនិងការដេញថ្លៃតាមរយៈ៖

www.clearcambodia.org, Khmer 24, www.BangThom.com

ការទទួលពាក្យដេញថ្លៃនេះចាប់ផ្តើមពីថ្ងៃទី២៧ ខែសីហា ឆ្នាំ២០២៤ រហូតដល់ថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២៤។

ភ្នំពេញ, ថ្ងៃទី២៨ ខែសីហា ឆ្នាំ២០២៤

ប្រធានរដ្ឋបាល និងធនធានមនុស្ស

លោក កេតុ ច័ន្ទតូ